អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ...148...
ថ្ងៃទី02.11.00...ម៉ោង10:00
បញ្ជូនទៅ...

# ព្រះរាជក្រម

នស/រកម/១០០០/០៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រី និង អំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រម លើពិធីសារលើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងស្តីពីគំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅទីក្រុងបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើក ទី ៣ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៗ.

# ច្បាប់

## ស្តីពីការអនុម័តយល់ព្រមលើពិធីសារលើការធ្វើវិសោធនកម្ម
## ទៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួម
## សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារលើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅទីក្រុងបាងកក នាថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារខាងលើនេះ ។៚

រាជធានីភ្នំពេញថ្ងៃទី២១ ខែ តុលា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

លេខ : ១៩៦ ច.ល ហោ ណាំហុង .

ដើម្បីចម្លងប្រែក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែតុលា ឆ្នាំ២០០០

អគ្គលេខាធិការរាជរដ្ឋាភិបាល

# កិច្ចព្រមព្រៀងលើគំរោងតារាងពន្ធគយអនុគ្រោះរួម
# ( CEPT ) សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ( AFTA )

សិង្ហបុរី,ថ្ងៃទី២៨ មករា ១៩៩២

## AGREEMENT ON THE COMMON EFFECTIVE PREFERENTIAL TARIFF (CEPT ) SCHEME FOR THE ASEAN FREE TRADE AREA ( AFTA )

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ សាធារណរដ្ឋឥណ្ឌូណេស៊ី ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៏ ជាប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN ) :

ដោយគោរពយល់ សេចក្ដីប្រកាស នៃកិច្ចព្រមព្រៀង ASEAN ដែលបានចុះហត្ថលេខានៅបាលី ប្រទេស ឥណ្ឌូណេស៊ី នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលបានចែងថា ប្រទេសដែលជាសមាជិកទាំងអស់ ត្រូវតែធ្វើ សហប្រតិបត្តិការនៅក្នុងវិស័យពាណិជ្ជកម្ម ដើម្បីជំរុញការអភិវឌ្ឍន៍ និងកំណើនផលិតកម្មថ្មី និង ពាណិជ្ជកម្ម

ដោយរំលឹកថា ប្រមុខរដ្ឋាភិបាលប្រទេសសមាជិកអាស៊ាន បានប្រកាសនៅក្នុងកិច្ចប្រជុំកំពូលលើកទី៣ របស់ខ្លួន ដែលធ្វើឡើងនៅទីក្រុងម៉ានីលពីថ្ងៃ១៣ - ១៥ ខែធ្នូ ឆ្នាំ១៩៨៧ ថាប្រទេសសមាជិក ត្រូវតែពង្រឹង សហប្រតិបត្តិការសេដ្ឋកិច្ចក្នុងប្រទេសសមាជិកអាស៊ាន ដើម្បីធ្វើអោយសំរេចជាអតិបរិមានូវសមិទ្ធិផលនៃ សក្ដានុពលតំបន់ក្នុងផ្នែកពាណិជ្ជកម្ម និង អភិវឌ្ឍន៍

ដោយកត់សំគាល់ ថាកិច្ចព្រមព្រៀងស្ដីពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (ASEAN PTA) ដែលបាន ចុះហត្ថលេខានៅទីក្រុង ម៉ានីល នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ ផ្ដល់នូវការអនុម័តវិធីជាច្រើនលើការ ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានអនុគ្រោះមួយ

ដោយគោរពតាម គោលការណ៍ ទស្សនៈ និងគំនិតទាំងឡាយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌលើការលើកកំពស់សហប្រតិបត្តិការសេដ្ឋកិច្ច ASEAN ដែលបានចុះហត្ថលេខានៅទីក្រុងសិង្ហបុរី នាថ្ងៃទី២៨ ខែ មករា ឆ្នាំ១៩៩២

ដោយជឿជាក់ថា កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ានទឹងធ្វើជាកត្តាជំរុញមួយដើម្បីពង្រឹងការផ្លាស់ប្តូរសេដ្ឋកិច្ចជាតិនិងអាស៊ាន ព្រមទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនៃបណ្តាប្រទេសសមាជិកនិមួយៗ តាមរយៈការពង្រឹងនូវកាលានុវត្តភាពវិនិយោគ ផលិតកម្ម ពាណិជ្ជកម្ម និង ចំណូលរូបិយប័ណ្ណបរទេស

ដោយសំរេចចិត្ត បង្កើនកិច្ចសហប្រតិបត្តិការផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ដោយការជំរុញសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្ម និងការវិនិយោគទុនក្នុងរង្វង់អាស៊ាន ក្នុងគោលដៅបង្កើតឡើងនូវតំបន់ពាណិជ្ជកម្មសេរីរបស់អាស៊ាន ដោយប្រើគំរោងអនុគ្រោះពន្ធគយរួម

ដោយចាប់ចំណង់ ធ្វើអោយមានប្រសិទ្ធិភាពឡើង លើកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មអាស៊ាន ដោយ យោងទៅតាមកិច្ចសន្យាជាអន្តរជាតិរបស់អាស៊ាន ។

## បានព្រមព្រៀងដូចខាងក្រោម:

## មាត្រា១

## និយមន័យ

គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១. គំរោងអនុគ្រោះពន្ធគយរួម ( CEPT ) គឺជាការព្រមព្រៀង លើការអនុគ្រោះពន្ធគយ សំរាប់អាស៊ាន ដែលអនុវត្តន៍ចំពោះទំនិញមានប្រភពដើមពីបណ្តាប្រទេសសមាជិកអាស៊ាន ហើយដែលបានដាក់បញ្ចូលទៅក្នុងគំរោងអនុគ្រោះពន្ធគយរួម ( CEPT ) ដោយអនុលោមទៅតាមមាត្រាទី ២ (៥) និង ទី៣ ។

២. របាំងពាណិជ្ជកម្មមិនមែនពន្ធគយ ( Non-Tariff Barriers ) គឺជាវិធានការណ៍ទាំងឡាយណាក្រៅពីពន្ធគយ ដែលហាមឃាត់ ឬដាក់កំរិតលើកូតាដោយមានប្រសិទ្ធិភាពក្នុងការនាំចូល ឬនាំចេញផលិតផលនៅក្នុងបណ្តាប្រទេសជាសមាជិក ។

៣. ការកំរិតបរិមាណ ( Quantitative Restriction) គឺជាការហាមឃាត់ ឬការដាក់កំរិតលើកូតាពាណិជ្ជកម្ម

ជាមួយបណ្តាប្រទេសដែលជាសមាជិកផ្សេងទៀត ទោះជាធ្វើឡើងតាមរយៈការកំរិតចំនួន ( Quotas ) អាជ្ញាប័ណ្ណ ឬតាមរយៈវិធានការណ៍ដែលមានប្រសិទ្ធភាពស្មើគ្នាផ្សេងទៀត រួមទាំងវិធានការណ៍ និងសេចក្តីតំរូវផ្នែករដ្ឋបាលផ្សេងៗទៀត ដែលដាក់កំរិតពាណិជកម្ម ។

៤. ការដាក់កំរិតលើការប្តូររូបិយប័ណ្ណបរទេស ( Foreign Exchange Restriction ) គឺជាវិធានការណ៍ដែលអនុវត្តដោយបណ្តាប្រទេសជាសមាជិកក្នុងទំរង់នៃការកំរិតលក្ខខ័ណ្ឌ និងបែបបទរដ្ឋបាលផ្សេងៗទៀតក្នុងការដោះដូររូបិយប័ណ្ណបរទេសដែលមានឥទ្ធិពលដល់ការដាក់កំរិតលក្ខខ័ណ្ឌផ្នែកពាណិជ្ជកម្ម ។

៥. PTA គឺជាការសំរួលអនុគ្រោះពាណិជ្ជកម្មរបស់អាស៊ាន ដែលមានក្នុងកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មរបស់អាស៊ាន ចុះហត្ថលេខានៅទីក្រុង ម៉ានីល នាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៧៧ និងមានក្នុងពិធីសារស្តីពីការធ្វើអោយមានភាពប្រសើរឡើងលើការពង្រីកការអនុគ្រោះពន្ធគយក្រោមកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មរបស់អាស៊ាន ( ASEAN PTA ) ដែលបានចុះហត្ថលេខា នៅទីក្រុងម៉ានីលនាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៨៧ ។

៦. បញ្ជីលើកលែង ( Exclusion List ) គឺជាបញ្ជីផលិតផលផ្សេងៗ ដែលមិនរាប់បញ្ចូលនៅក្នុងការពង្រីកការអនុគ្រោះពន្ធគយក្រោមគំរោងអនុគ្រោះពន្ធគយរួម ( CEPT ) ។

៧. ផលិតផលកសិកម្ម គឺ :

ក- វត្ថុធាតុដើមកសិកម្ម ឬផលិតផលមិនទាន់កែច្នៃដែលស្ថិតនៅក្នុងជំពូក ១ - ២៤ របស់ប្រព័ន្ធស៊ីសង្វាក់គ្នា Harmonize System ( HS ) និងវត្ថុធាតុដើមកសិកម្ម ឬ ផលិតផលមិនទាន់កែច្នៃស្រដៀងគ្នាផ្សេងៗទៀតនៅក្នុងទីតាំងតារាងពន្ធគយនៃប្រព័ន្ធស៊ីសង្វាក់គ្នា Harmonize System(HS ) ដទៃទៀត ។

ខ- ផលិតផលទាំងឡាយណាដែលទទួលរងនូវការកែច្នៃសាមញ្ញ ដែលមានការផ្លាស់ប្តូរទ្រង់ទ្រាយបន្តិចបន្តួចពីផលិតផលដើម ។

## មាត្រា២

## បទបញ្ញត្តិទូទៅ

១. ប្រទេសជាសមាជិកទាំងអស់ ត្រូវចូលរួមក្នុងគំរោង CEPT ។

២. អត្តសញ្ញាណកម្ម របស់ផលិតផលដែលត្រូវបានដាក់បញ្ចូលទៅក្នុងគំរោង CEPT ត្រូវឈរលើមូលដ្ឋានតាមផ្នែក មានន័យថានៅកំរិត៦ខ្ទង់របស់ប្រព័ន្ធស្របគ្នា HS ។

៣. ការមិនរាប់បញ្ចូលទៅកំរិតខ្ទង់ ៨/៩ HS របស់ប្រព័ន្ធស្របគ្នា ចំពោះផលិតផលពិសេសត្រូវបាន អនុញ្ញាតជាបណ្ដោះអាសន្នដល់ប្រទេសជាសមាជិកទាំងឡាយ ដែលមិនទាន់បានត្រៀមរួចរាល់ក្នុងការដាក់បញ្ចូលផលិតផលទាំងនោះទៅក្នុងគំរោង CEPT ។ ចំពោះផលិតផលពិសេស ដែលមានផលប៉ះពាល់ដល់បណ្ដាប្រទេសសមាជិក យោងទៅតាមមាត្រា ១ (៣) នៃគំរោងកិច្ចព្រមព្រៀងស្ដីអំពីការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ប្រទេសជាសមាជិកអាចដកផលិតផលទាំងនោះពីគំរោង CEPT យោងតាមលិខិតបដិសេធលើសម្បទានណាមួយ ដែលមានចែងចំពោះផលិតផលនោះ។ ការពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តនៅឆ្នាំទី៨ ដើម្បីសំរេចលើបញ្ជីទំនិញលើកលែងឬ ក៏ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ។

៤. ផលិតផលដែលត្រូវបានចាត់ទុកថាជាផលិតផលមានដើមកំណើតពីបណ្ដាប្រទេសជាសមាជិកអាស៊ានណាមួយ លុះត្រាតែយ៉ាងហោចណាស់ក៏៤០%នៃធាតុផ្សំនៃផលិតផលទាំងនោះមានប្រភពដើមចេញពីប្រទេសសមាជិកអាស៊ានណាមួយ ។

៥. រាល់ផលិតផលឧស្សាហកម្មទាំងអស់ រួមទាំងមុខទំនិញមូលធន ផលិតផលកសិកម្មកែច្នៃ និងរាល់ផលិតផលទាំងអស់ ដែលនៅក្រៅវង្វង់កសិផល ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឋិតក្នុងគំរោង CEPT ។ ផលិតផលទាំងនោះ ត្រូវបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងកម្មវត្ថុនៃកម្មវិធីកាត់បន្ថយពន្ធគយដូចដែលបានចែងនៅក្នុងមាត្រា៤ នៃកិច្ចព្រមព្រៀង។ ដោយយោងទៅតាមមុខទំនិញផ្សេងៗនៅក្នុង PTA កម្មវិធីនៃការកាត់បន្ថយពន្ធគយនៅក្នុងមាត្រា៤នៃកិច្ចព្រមព្រៀងនេះ ត្រូវតែបានអនុវត្តដោយយកមកពិចារណាអំពីអត្រាពន្ធគយ បន្ទាប់ពីការអនុវត្តន៍កំរិតនៃការអនុគ្រោះ (MOP ) នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩២ ។

៦. ផលិតផលទាំងអស់ដែលស្ថិតនៅក្រោម PTA ហើយដែលមិនបានផ្ទេរបញ្ចូលទៅក្នុងគំរោង CEPT នឹងត្រូវបន្តអនុវត្តតាម MOP ដែលមានស្រាប់រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩២ ។

៧.

បណ្ដាប្រទេសសមាជិកដែលបានយល់ព្រមកាត់បន្ថយពន្ធគយលើផលិតផលដែលមានអត្រាពន្ធគយ២០%និងក្រោម២០% ទៅដល់ ៥%-០% ទោះបីជាត្រូវបានផ្ដល់ MFN ក៏ដោយត្រូវតែទទួលបាននូវសម្បទានទាំងនោះ។ បណ្ដាប្រទេសជាសមាជិកដែលមានអត្រាពន្ធក្នុងកំរិតអត្រា MFN មានកំរិត 0-៥% នឹងត្រូវបានគេចាត់ទុកថា បានបំពេញកាតព្វកិច្ច តាមកិច្ចព្រមព្រៀងនេះ និង ត្រូវបានទទួលសម្បទានផងដែរ ។

## មាត្រា៣

## ចំនួនផលិតផល

កិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តចំពោះផលិតផលកម្មន្តសាលទាំងអស់ រួមមានទាំងមុខទំនិញ មូលធន ផលិតផលកសិកម្មកែច្នៃ និងផលិតផលទាំងអស់ដែលនៅក្រៅរង្វង់កសិផល ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។ ផលិតផលកសិកម្មត្រូវតែដកចេញពីគំរោង CEPT ។

## មាត្រា៤

## កម្មវិធីកាត់បន្ថយពន្ធគយ

១. បណ្តាប្រទេសសមាជិក បានឯកភាពលើកម្មវិធីកាត់បន្ថយពន្ធគយ ដូចខាងក្រោម :

ក- ការបន្ថយអត្រាពន្ធគយដែលមាន អោយមកត្រឹម ២០%ត្រូវធ្វើអោយហើយក្នុងរយៈពេល៥ឆ្នាំទៅ៨ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ១ មករា ១៩៩៣ កម្មវត្ថុនៃកម្មវិធីការកាត់បន្ថយពន្ធគយត្រូវសំរេចដោយប្រទេសសមាជិកនិមួយៗ ហើយត្រូវផ្សព្វផ្សាយកម្មវិធីនេះនៅពេលចាប់ផ្តើមអនុវត្ត ។ ប្រទេសសមាជិកត្រូវបានលើកទឹកចិត្ត ចំពោះការយល់ព្រមកាត់បន្ថយអត្រាពន្ធគយប្រចាំឆ្នាំគឺ (X–20)% ក្នុង៥ ឬ ៨ឆ្នាំ ដែល X ស្មើនឹងអត្រាពន្ធគយដែលមានក្នុងពេលបច្ចុប្បន្ន របស់បណ្តាប្រទេសជាសមាជិកនីមួយៗ ។

ខ- ការបន្ថយអត្រាពន្ធគយជាបន្តបន្ទាប់ពី ២០% ឬក្រោម ២០%ត្រូវតែធ្វើឡើងក្នុងរយៈពេល៧ឆ្នាំ។ អត្រាពន្ធគយត្រូវបន្ថយជាអប្បបរិមា ៥% ក្នុងការបន្ថយមួយលើកៗ។ កម្មវិធីនៃការកាត់បន្ថយពន្ធគយ ដែលបានសំរេចដោយប្រទេសសមាជិកនីមួយៗ ត្រូវតែប្រកាសនៅពេលចាប់ផ្តើម អនុវត្តកម្មវិធីនេះ ។

គ- ចំពោះបណ្តាផលិតផលដែលមានអត្រាពន្ធគយ ២០% ឬក្រោម ២០% នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៣ បណ្តាប្រទេសសមាជិកត្រូវសំរេចលើកម្មវិធីនៃការបន្ថយពន្ធគយ ហើយត្រូវប្រកាសផ្សាយកម្មវិធីនៃការបន្ថយពន្ធគយនៅពេលចាប់ផ្តើមអនុវត្ត ។ ប្រទេសជាសមាជិកពីរ ឬច្រើនអាចធ្វើការសំរុះសំរួលក្នុងការកាត់បន្ថយពន្ធពី ០%-៥% លើផលិតផលពិសេសតាមការបង្កើនល្បឿន តែត្រូវប្រកាសនៅពេលចាប់ផ្តើមកម្មវិធីនេះ ។

២. ដោយអនុលោមទៅតាមមាត្រា៤( ១ )( ខ ) និង៤( ១ )( គ )នៃកិច្ចព្រមព្រៀងនេះ បណ្តាផលិតផល ដែលមានអត្រាពន្ធគយ ២០% ឬក្រោម ២០% នឹងត្រូវទទួលសម្បទានដោយស្វ័យប្រវត្តិ ។

៣. កម្មវិធីកាត់បន្ថយពន្ធគយខាងលើ មិនរារាំងដល់បណ្តាប្រទេសសមាជិកក្នុងការកាត់បន្ថយពន្ធគយភ្លាមៗ ឱ្យមកនៅត្រឹម ០%-៥%ឬការបង្កើនល្បឿននៃការកាត់បន្ថយពន្ធគយរបស់គេ ។

## មាត្រា៥

## បញ្ញត្តិផ្សេងៗ

ក. ការកំរិតបរិមាណ និងរបាំងពាណិជ្ជកម្មមិនមែនពន្ធគយ

១. បណ្តាប្រទេសសមាជិកត្រូវលុបបំបាត់រាល់ការកំរិតបរិមាណទាំងអស់ ដែលទាក់ទងទៅនឹងបណ្តាផលិតផលដែលស្ថិតនៅក្រោមគំរោង CEPT លើការទទួលសម្បទានដែលអាចអនុវត្ត ចំពោះបណ្តាផលិតផលទាំងអស់ ។

២. បណ្តាប្រទេសសមាជិកទាំងអស់ត្រូវលុបបំបាត់ចោលនូវរបាំងមិនមែនពន្ធគយដទៃទៀតជាជំហាន១ ក្នុង រយៈពេល ៥ ឆ្នាំបន្ទាប់ពីការទទួលសម្បទាន ដែលអាចអនុវត្តចំពោះផលិតផលទាំងនោះ ។

ខ. ការដាក់កំរិតលើផ្នែកហិរញ្ញវត្ថុលើការប្តូររូបិយប័ណ្ណបរទេស

បណ្តាប្រទេសសមាជិកត្រូវធ្វើការលើកលែងចំពោះការកំរិតនូវការប្តូររូបិយប័ណ្ណបរទេស ដែលទាក់ទងទៅនឹងការទូទាត់សំរាប់ផលិតផលដែលស្ថិតនៅក្រោមគំរោង CEPT ព្រមទាំងការបញ្ជូនមកវិញនូវការទូទាត់ទាំងនោះ ដោយគ្មានបែងចែកចំពោះសិទ្ធរបស់បណ្តាប្រទេសទាំងនោះ ដែលមានចែងក្នុងមាត្រាទី XVIII នៃកិច្ចព្រមព្រៀង ទូទៅស្តីអំពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ហើយនិងបញ្ញត្តិពាក់ព័ន្ធនៃមាត្រាទាំងឡាយរបស់កិច្ចព្រមព្រៀង អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ( IMF ) ។

គ. កិច្ចសហប្រតិបត្តិការលើវិស័យផ្សេងទៀត

បណ្តាប្រទេសសមាជិកត្រូវស្វែងរកនូវវិធានការច្រើនថែមទៀត លើវិស័យសហប្រតិបត្តិការមាន កំរិត និង មិនមានកំរិត ដើម្បីបំពេញបង្រួប និងបន្ថែមនូវសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ វិធានការទាំងនោះអាចរួមបញ្ចូលជា មួយវិធានការដទៃផ្សេងទៀតនូវប្រព័ន្ធស្របគ្នា ការទទួលស្គាល់ទៅវិញទៅមកនូវការធ្វើតេស្ត និងលិខិតបញ្ជាក់លើ ផលិតផលផ្សេង១ ការលុបបំបាត់នូវរបាំងចំពោះវិនិយោគទុនបរទេស ការពិគ្រោះ យោបល់ម៉ាក្រូសេដ្ឋកិច្ច ច្បាប់នានា សំរាប់ការប្រកួតប្រជែងស្មើភាព និងសាជីវកម្មមូលធន ។

ឃ. ការរក្សានូវសម្បទាន

បណ្តាប្រទេសជាសមាជិកមិនត្រូវធ្វើឱ្យទៅជាមោឃៈ ធ្វើអោយខូចដល់សម្បទានណាមួយ ដែលបានព្រមព្រៀងតាមរយៈការអនុវត្តវិធីផ្សេង១ នៃការវាយតំលៃរបស់គយ កំរៃថ្មីណាមួយផ្សេងទៀត ឬក៏វិធានការណ៍ថ្មីផ្សេងទៀត ដែលដាក់កំរិតដល់ពាណិជ្ជកម្ម លើកលែងតែក្នុងបណ្តាករណីដែលចែងក្នុងកិច្ចព្រមព្រៀងនេះ ផ្តល់អោយ ។

## មាត្រា៦
## វិធានការបន្ទាន់

១. បើធ្វើអោយការនាំចូលផលិតផលណាមួយតាមគំរោង CEPT កើនឡើងក្នុងរបៀបមួយដែលគំរាមកំហែង ឬបណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរដល់ផ្នែកផលិតកម្ម ឬ ដល់ផលិតផលប្រកួតប្រជែងដោយផ្ទាល់នៅក្នុងបណ្តាប្រទេសនាំចូលជាសមាជិក គេអាចព្យួរការអនុគ្រោះជាបណ្តោះអាសន្ន និង ដោយគ្មានរើសអើង យោងតាមមាត្រា៦ (៣) នៃកិច្ចព្រមព្រៀងនេះចំពោះទំហំ និង ពេលវេលាដែលអាចចាំបាច់ដើម្បីទប់ស្កាត់ ឬ ដើម្បីដោះស្រាយការខូចខាតនោះ។ ការព្យួរការអនុគ្រោះជាបណ្តោះអាសន្ននេះត្រូវតែស្របទៅតាម GATT ។

២. ដោយគ្មានការបែងចែកចំពោះកាតព្វកិច្ចអន្តរជាតិដែលមានស្រាប់ ប្រទេសជាសមាជិកមួយដែលយល់ឃើញថាចាំបាច់ត្រូវបង្កើត ឬបង្កើតការកើត ឬកើតការនាំចូលក្នុងន័យបង្ការការគំរាម ឬបញ្ឈប់ការថយចុះយ៉ាងច្រើននៃទុនបំរុងរូបិយវត្ថុ ប្រទេសនេះត្រូវតែខំប្រឹងប្រែងធ្វើដូច្នេះក្នុងរបៀបណាមួយ ដែលការពារតំលៃនៃសម្បទានទាំងឡាយដែលបានយល់ព្រមរួចមកហើយ ។

៣. ទៅកន្លែងណាដែលវិធានការលើបន្ទាន់ ត្រូវបានយកមកអនុវត្តអនុលោមតាមមាត្រានេះ សេចក្តីប្រកាសជាបន្ទាន់នៃសកម្មភាពទាំងនេះ ត្រូវតែផ្តល់ទៅអោយក្រុមប្រឹក្សា យោងទៅតាមមាត្រា៧នៃកិច្ចព្រមព្រៀងនេះ ហើយសកម្មភាពទាំងនេះ អាចស្ថិតនៅក្រោមការពិគ្រោះដូចបានចែងនៅក្នុងមាត្រា៨ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៧
## ការរៀបចំស្ថាប័ន

១. ដើម្បីគោលបំណងនៃកិច្ចព្រមព្រៀងនេះ បណ្តារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ( AEM ) ត្រូវបង្កើតក្រុមប្រឹក្សា ថ្នាក់រដ្ឋមន្ត្រី ដែលរួមមានសមាជិកជ្រើសតាំងម្នាក់មកពីប្រទេសសមាជិកនិមួយៗ និងអគ្គលេខាធិការនៃលេខាធិការដ្ឋានអាស៊ាន ។ លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ការឧបត្ថម្ភដល់ក្រុមប្រឹក្សាថ្នាក់រដ្ឋមន្ត្រីដើម្បីត្រួតពិនិត្យ សំរបសំរួល និងដើម្បីពិនិត្យឡើងវិញលើការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ និងជួយដល់បណ្តារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើគ្រប់បញ្ហាដែលទាក់ទងការអនុវត្តន៍នោះ។ ក្នុងការបំពេញតួនាទីរបស់ខ្លួនក្រុមប្រឹក្សាថ្នាក់រដ្ឋមន្ត្រី ត្រូវតែបានឧបត្ថម្ភគាំទ្រផងដែរ ដោយឧត្តមមន្ត្រីសេដ្ឋកិច្ច ( SEOM ) ។

២. បណ្ដាប្រទេសជាសមាជិក ដែលបានព្រមព្រៀងជាទ្វេភាគីស្ដីពីការកាត់បន្ថយពន្ធគយ ស្របតាម មាត្រា៤ នៃកិច្ចព្រមព្រៀងនេះ ត្រូវផ្ដល់ដំណឹងដល់បណ្ដាប្រទេសជាសមាជិកដទៃទៀត និងលេខាធិការដ្ឋានអាស៊ានពីកិច្ចព្រមព្រៀងនេះ ។

៣. លេខាធិការដ្ឋានអាស៊ានត្រូវត្រួតពិនិត្យតាមដាន និងរាយការណ៍ជូន SEOM ចំពោះការអនុវត្តន៍កិច្ចព្រមព្រៀងស្របតាមមាត្រា III (២)(៨) នៃកិច្ចព្រមព្រៀងស្ដីអំពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ។ ប្រទេសជាសមាជិក ត្រូវតែសហការជាមួយលេខាធិការដ្ឋានអាស៊ាន ក្នុងការបំពេញតួនាទីរបស់ខ្លួន ។

## មាត្រា៨

## ការពិគ្រោះយោបល់

១. បណ្ដាប្រទេសជាសមាជិក ត្រូវផ្ដល់នូវកាលានុវត្តភាពសមល្មមសំរាប់ការពិគ្រោះយោបល់ ចំពោះការលើកឡើងទាំងឡាយដែលប្រទេសជាសមាជិកដទៃទៀតធ្វើឡើងទាក់ទងនឹងបញ្ហាណាមួយ ដែលប៉ះពាល់ដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។ យោងតាមមាត្រា ៧ នៃកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាអាចរិះរកវិធានការណ៍ណែនាំពីបណ្ដារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ទាក់ទងទៅនឹងបញ្ហាណាមួយដែលមិនអាចមានលទ្ធភាពរកឃើញនូវដំណោះស្រាយមួយសមស្របក្នុងកំឡុងពេលពិគ្រោះយោបល់កន្លងមក ។

២. បណ្ដាប្រទេសជាសមាជិកដែលយល់ឃើញថា ប្រទេសជាសមាជិកណាមួយមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ដែលបណ្ដាលឱ្យមានការបាត់បង់ទាំងស្រុង ឬបាត់បង់ផ្នែកមួយនៃផលប្រយោជន៍ណាមួយដែលប្រទេសជាសមាជិកត្រូវទទួលបណ្ដាប្រទេសជាសមាជិកអាចលើកឡើង ឬលើកសំណើចំពោះប្រទេសដែលជាសមាជិកពាក់ព័ន្ធ ត្រូវតែធ្វើការពិចារណាការលើកឡើង ឬការលើកសំណើរចំពោះបញ្ហានេះ ដើម្បីធ្វើអោយសំរេចដល់ការកែតម្រូវដ៏សមស្របលើបញ្ហានោះ។

៣. ទំនាស់ណាមួយរវាងបណ្ដាប្រទេសជាសមាជិក ដែលទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងនេះនឹងត្រូវដោះស្រាយដោយមិត្តភាពរវាងគូភាគីនានា អោយអស់តាមលទ្ធភាព។ ប្រសិនភាពខុសគ្នាទាំងឡាយណាមិនអាចដោះស្រាយដោយមិត្តភាពទេ គេត្រូវតែដាក់បញ្ហានេះជូនទៅក្រុមប្រឹក្សា យោងតាមមាត្រា ៧ នៃកិច្ចព្រមព្រៀង ហើយប្រសិនបើចាំបាច់ត្រូវដាក់ជូនទៅ AEM ។

## មាត្រា៩

## ការលើកលែងជាទូទៅ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ រារាំងប្រទេសជាសមាជិកណាមួយពីការធ្វើសកម្មភាព ឬ អនុម័តវិធានការ ដែលគេយល់ឃើញថាចាំបាច់សំរាប់កិច្ចការការពារសន្តិសុខជាតិ ការពារសីលធម៌សាធារណៈការពារ

ជីវិត និងសុខភាព របស់មនុស្ស សត្វនិងរុក្ខជាតិ ព្រមទាំងការពារទ្រព្យសម្បត្តិ ដែលមានតំលៃសិល្បៈ តំលៃប្រវត្តិសាស្ត្រ និង តំលៃបុរាណវត្ថុវិទ្យា ។

## មាត្រា១០

## អវសានបញ្ញត្តិ

១. រដ្ឋាភិបាលនីមួយៗនៃបណ្តាប្រទេសជាសមាជិកត្រូវអនុវត្តដោយសមរម្យតាមច្បាប់ទាំងឡាយ ដែលចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

២. វិសោធនកម្មណាមួយចំពោះកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងដោយការឯកភាពជាទូទៅ ហើយចូលជាធរមាននៅពេលដែលគ្រប់បណ្តាប្រទេសជាសមាជិកទាំងអស់ទទួលស្គាល់ ។

៣. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន នៅពេលចុះហត្ថលេខា ។

៤. កិច្ចព្រមព្រៀងនេះ ត្រូវតំកល់ជាមួយអគ្គលេខាធិការអាស៊ាន ហើយអគ្គលេខាត្រូវផ្តល់ច្បាប់ចំលងដែល មានសេចក្តីបញ្ជាក់ ដល់ប្រទេសជាសមាជិកនិមួយៗជាបន្ទាន់ ។

៥. គ្មានការមិនឯកភាពណាមួយត្រូវបានធ្វើឡើងចំពោះបទបញ្ញត្តិណាមួយ នៃបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

ដើម្បីជាសក្ខីភាព ហត្ថលេខី ដែលបានទទួលសិទ្ធប្រទានយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាល និមួយៗរបស់គេ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីតំរោង CEPT សំរាប់ AFTA ។

ធ្វើនៅសិង្ហបុរី នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២ មួយច្បាប់ជាភាសាអង់គ្លេស ។

តំណាងរដ្ឋាភិបាលរបស់ប្រទេសប្រ៊ុយណេដារូសាឡាំ

អាប់ឌុល រ៉ាម៉ាន់ តាអ៊ីប

រដ្ឋមន្ត្រីឧស្សាហកម្មនិងប្រភពធនធាន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

ដ្រារីហ្វីន ម. ស៊ីរេគ្គា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលរបស់ម៉ាឡេស៊ី

រ៉ាហ្វីដាស អាហ្ស៊ីស

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេសនិងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

ពីធើ ឌុ. គ្មារូចូ ស្ទីអ

រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

លី សៀង លូង

ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ដ៍

អាម៉ារេត ស៊ីឡា អូន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ឧបសម្ព័ន្ធ ក

## ពិធីសារលើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោង
## អនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA)

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ សាធារណរដ្ឋឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី និងព្រះរាជាណាចក្រថៃដែលជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ "អាស៊ាន"

<u>ដោយកត់សំគាល់</u> លើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួម (CEPT) សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានដែលបានចុះហត្ថលេខានៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩២

<u>ដោយរំលឹកឡើងវិញ</u> អំពីពិធីសារនៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន "១៩៩២" ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋាភិបាលនៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ដែលឆ្លុះបញ្ចាំងនូវការបង្កើនល្បឿននៃគំរោងអនុគ្រោះពន្ធគយរួម (CEPT)សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានចាប់ពីឆ្នាំ ២០០៨ ចុះមកឆ្នាំ ២០០៣ វិញ។

<u>ដោយទទួលស្គាល់</u> លើការចាំបាច់ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ថ្មីៗនៅក្នុងអាស៊ាន

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ :

### មាត្រា ១

មាត្រា ២ កថាខ័ណ្ឌទី ៣ . ៥ និង ទី៦នៃកិច្ចព្រមព្រៀងត្រូវបានធ្វើវិសោធនកម្មហើយត្រូវអានដូចខាងក្រោមនេះ :

៣. ការលើកលែងនៅក្នុងប្រព័ន្ធចុះសំរុងគ្នា ( Harmonized System - HS ) ដែលមាន៨/៩ខ្ទង់ សំរាប់ទំនិញជាកំលាក់ត្រូវបានអនុញ្ញាតចំពោះប្រទេសសមាជិកដែលពុំទាន់ត្រៀមខ្លួនចូលជាស្រេចក្នុងការ

ដាក់បញ្ចូលទំនិញនោះទៅក្នុង CEPT ។ សំរាប់ទំនិញជាក់លាក់ដែលមានវិទយិតភាព (Sensitive)' ចំពោះប្រទេសជាសមាជិក . អនុលោមទៅតាមមាត្រា ១ (៣) នៃក្រិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន . ប្រទេសជាសមាជិកអាចដកទំនិញចេញពីគំរោង CEPT ប៉ុន្តែមិនអាចទទួលសម្បទានដែលគេផ្តល់ឱ្យចំពោះទំនិញប្រភេទនេះបានឡើយ ។ ទំនិញដែលដកចេញជាបណ្តោះអាសន្នទាំងនេះត្រូវដាក់បញ្ចូលជាបន្តបន្ទាប់មកក្នុង CEPT រហូតនៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០០ ។

៥. ឧស្សាហផលសំរេចរួមទាំងទំនិញមូលធន និងផលិតផលកសិកម្មផងនឹងត្រូវ ស្ថិតនៅក្នុងគំរោង CEPT ។ ទំនិញទាំងនោះជាស្វ័យប្រវត្តិត្រូវស្ថិតនៅក្រោមកម្មវិធីកាត់បន្ថយពន្ធ ដែលមានចែងក្នុងមាត្រាទី ៤ នៃកិច្ចព្រមព្រៀងដែលបានកែសំរួលឡើងវិញនៅក្នុងមាត្រា ៣ នៃពិធីសារនេះ ។ ដោយយោងដល់ទំនិញនៅក្នុងកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម PTA . កម្មវិធី កាត់បន្ថយពន្ធដែលមានចែងនៅក្នុងការកែសំរួលឡើងវិញក្នុងមាត្រាទី ៤ "ក" ដែល ចែងនៅក្នុងមាត្រា ៣ នៃពិធីសារនេះនឹងត្រូវអនុវត្តដោយត្រូវយកចិត្តទុកដាក់ដល់អត្រាពន្ធ បន្ទាប់ពីការអនុវត្តន៍ នៃកំរិតដែលមានស្រាប់នៃការអនុគ្រោះពន្ធគយ(Margin of Preference - MOP ) ដែលលើកឡើង នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩២ ។

## មាត្រា ២

មាត្រា ៣ នៃកិច្ចព្រមព្រៀងត្រូវធ្វើវិសោធនកម្មនិងត្រូវអានដូចខាងក្រោមនេះ :

"កិច្ចព្រមព្រៀងនេះនឹងអនុវត្តទៅលើឧស្សាផលសំរេចរួមទាំង ទំនិញមូលធន ផង និងផលិតផលកសិកម្មផង"

## មាត្រា ៣

មាត្រា ៤ នៃកិច្ចព្រមព្រៀងត្រូវបានប្តូរដូចខាងក្រោម :

កម្មវិធីនៃការកាត់បន្ថយពន្ធគយនិងការទទួលសម្បទាន

I. **កម្មវិធីនៃការកាត់បន្ថយពន្ធគយ**

១. ប្រទេសសមាជិកព្រមព្រៀងលើកម្មវិធីនៃការកាត់បន្ថយពន្ធគយអនុគ្រោះដូចខាងក្រោម :

ក. ការកាត់បន្ថយពន្ធលើអត្រាមានស្រាប់២០%ត្រូវសំរេចរយៈពេល ៥ ឆ្នាំគិតចាប់ថ្ងៃទី០១ ខែ មករា ឆ្នាំ ១៩៩៣ ដោយគោរពកម្មវិធីនៃកាត់បន្ថយពន្ធគយដែលត្រូវបានសំរេចដោយប្រទេសសមាជិកនិមួយៗ ដែលនឹងត្រូវគេប្រកាសនៅពេលចាប់ផ្តើមកម្មវិធី ។ ប្រទេសសមាជិកត្រូវបានលើកទឹកអោយអនុម័តអត្រាពន្ធគយកាត់បន្ថយប្រចាំឆ្នាំដែលមានរូបមន្ត (X - 20) %/5 ដែល X ស្មើនិងអត្រាពន្ធគយមានស្រាប់នៃប្រទេសសមាជិកនីមួយៗ ។

ខ.ការកាត់បន្ថយពន្ធគយបន្ទាប់ពីអត្រា ២០% ឬទាបជាងត្រូវរក្សារយៈពេល៥ឆ្នាំ។ អត្រាពន្ធគយដែលត្រូវកាត់បន្ថយត្រូវមាន ៥% ជាអប្បបរិមាសំរាប់រាល់ការកាត់បន្ថយម្តង១។ កម្មវិធីកាត់បន្ថយពន្ធគយ ដែលត្រូវសំរេចដោយប្រទេសសមាជិកនិមួយ១ត្រូវប្រកាសនៅពេលចាប់ផ្តើមកម្មវិធី។

គ.ចំពោះផលិតផលដែលមានអត្រាពន្ធគយមានស្រាប់ ២០% ឬទាបជាងនៅ ថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៣ ប្រទេសសមាជិកត្រូវសំរេចលើកម្មវិធីនៃការកាត់បន្ថយពន្ធគយ កម្មវិធីកាត់បន្ថយនេះត្រូវប្រកាសនៅពេលចាប់ផ្តើមកម្មវិធី។

២. កម្មវិធីកាត់បន្ថយពន្ធខាងលើមិនហាមឃាត់ប្រទេសសមាជិកពីការកាត់បន្ថយអត្រាពន្ធគយមក ០% និង ៥%ភ្លាម១ឡើយ ឬពីការអនុវត្តន៍តាមកម្មវិធីបង្កើនល្បឿននៃការកាត់បន្ថយពន្ធ។

II . **ការទទួលសម្បទាន**

ដោយគោរពតាមមាត្រា 4(A)(1b) និង 4(A)(1c)នៃកិច្ចព្រមព្រៀងផលិតផលដែលមានអត្រា២០% ឬទាបជាងត្រូវទទួលសម្បទាន ជាស្វ័យប្រវត្តិ។

**មាត្រា ៤**

ឃ្លាដូចខាងក្រោមនេះត្រូវដាក់បញ្ចូលបន្ទាប់ពីមាត្រា ៩ ដូចមាត្រា ៩A ថ្មី នៃកិច្ចព្រមព្រៀង :

**ការចូលរួមរបស់សមាជិកថ្មី**

ប្រទេសសមាជិកថ្មីនៃអាស៊ាន ត្រូវចូលរួមកិច្ចព្រមព្រៀង នេះតាមកាល និងលក្ខខ័ណ្ឌដែលស្របទៅតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញសហប្រតិបត្តិសេដ្ឋកិច្ចអាស៊ាន ឆ្នាំ ១៩៩២ និងកិច្ចព្រមព្រៀងដែលបានព្រមព្រៀងរវាងសមាជិកថ្មី និងសមាជិកដែលមានស្រាប់។

**មាត្រា ៥**

ពិធីសារនេះនឹងចូលជាធរមាននៅពេលបានផ្តល់ឯកសារ អោយសច្ចានុម័ត ឬយល់ព្រមដោយរដ្ឋាភិបាលហត្ថលេខីទៅអគ្គលេខាធិការអាស៊ានមិនអោយយឺតជាង ថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៦។

ពិធីសារនេះនឹងត្រូវកំណត់ទុកដោយអគ្គលេខាធិការអស៊ានដែលត្រូវផ្តល់អោយប្រទេសសមាជិកនិមួយ១នៅច្បាប់ចំលងត្រឹមត្រូវមួយច្បាប់។

ដើម្បីជាសក្ខីភាព ហត្ថលេខីខាងក្រោមដែលត្រូវបានទទួលសិទ្ធិពីរដ្ឋាភិបាលរបស់ខ្លួនបានចុះហត្ថលេខាលើពិធីសារកែតំរូវតំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសាំងហ្គាពួរ

ហត្ថលេខា

YEO CHEOV TONG

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់ដ៍

ហត្ថលេខា

AMNUAY VIRAVAN

ឧបនាយករដ្ឋមន្ត្រី

ធ្វើនៅទីក្រុងបាំងកកថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៥ ជាភាសាអង់គ្លេសមួយច្បាប់

សំរាប់រដ្ឋាភិបាលប្រ៊ុយណេ

ហត្ថលេខា

ABDUL RAHMAN TAIB

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងវត្ថុធាតុដើម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី

ហត្ថលេខា

T.ARIQIBOWO

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលម៉ាឡេស៊ី

ហត្ថលេខា

RAFIDAHAZIZ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ហត្ថលេខា

RIZALINO S.NAVARRO

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

# កិច្ចព្រមព្រៀងរបស់អាស៊ាន អំពីបញ្ហាគយ

## ភូកិត ថ្ងៃទី១ មិនា ១៩៩៧

## ASEAN AGREEMENT ON CUSTOMS

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ សាធារណរដ្ឋឥណ្ឌូណេស៊ី ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( ខាងក្រោមនេះហៅថា "អាស៊ាន" )

ដោយកត់សំគាល់លើក្របខ័ណ្ឌកិច្ចព្រមព្រៀង ស្តីពីការបង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន កាលពី ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ១៩៩២ ដែលបានចែងថា ប្រទេសជាសមាជិកនឹងស្វែងរកវិធានការណ៍បន្ថែមទៀត អំពីព្រំដែន និង តំបន់គ្មានព្រំដែន សំរាប់កិច្ចសហប្រតិបត្តិការ ដើម្បីផ្តល់ និង ពង្រីកការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម ។

ដោយយកចិត្តទុកដាក់លើបញ្ហាថា នៅក្នុងឆ្នាំ ១៩៩២ ថ្នាក់ដឹកនាំនៃរដ្ឋាភិបាលប្រទេសអាស៊ានបានប្រកាសថា តំបន់ពាណិជ្ជកម្មសេរីអាស៊ីអាគ្នេយ៍ (ក្នុងនោះសំដៅលើ "AFTA" ) នឹងត្រូវបានគេបង្កើតឡើងនៅក្នុងតំបន់ ហើយក្នុងឆ្នាំ ១៩៩៥ គេបានឯកភាពធ្វើការបង្កើនល្បឿនការអនុវត្តន៍ត្រឹមឆ្នាំ២០០៣ ។

ដោយរំលឹកឡើងវិញថា ក្នុងឆ្នាំ ១៩៩៥ ថ្នាក់ដឹកនាំនៃរដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ានបានយល់ព្រម នៅក្នុងការប្រកាសនៃកិច្ចប្រជុំនៅទីក្រុងបាងកក របៀបវារៈសំរាប់កម្មវិធីដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចរវាងគ្នាទៅវិញទៅមក ការធ្វើអោយស៊ីសង្វាក់គ្នានៃតារាងពន្ធគយ និងការអនុវត្តន៍ប្រព័ន្ធវាយតំលៃ GATT ក្នុងឆ្នាំ១៩៩៧ ។

ដោយទទួលស្គាល់លើការបង្កើតប្រព័ន្ធច្រកបៃតង ( Green Line ) ក្រុមប្រឹក្សាទី៧របស់ AFTA ក៏បានឯកភាពផងដែរទៅលើការធ្វើអោយស៊ីសង្វាក់គ្នានៃនិតិវិធីគយផ្សេងៗ ។

ដោយយកចិត្តទុកដាក់ដល់កំរិតនៃការអភិវឌ្ឍន៍គយ និងសេដ្ឋកិច្ចផ្សេងៗគ្នា និងប្រវត្តិវប្បធម៌ខុសៗគ្នា នៃបណ្តាប្រទេសជាសមាជិកអាស៊ាន ។

ដោយរំលឹកឡើងវិញនូវការអនុវត្តន៍គោលការណ៍នៃកិច្ចព្រមព្រៀងទូទៅ ស្តីពីតារាងពន្ធគយ និង ពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ (ខាងក្រោមនេះហៅថា : "GATT ") កិច្ចព្រមព្រៀងបង្កើត អង្គការពាណិជ្ជកម្មពិភពលោក (ខាងក្រោម ហៅថា : "WTO ") និងអង្គការគយពិភពលោក (ខាងក្រោមនេះហៅថា : "WCO ") ។

ដោយរំលឹកឡើងវិញនូវក្រមដឹកនាំរបស់គយអាស៊ាន ដែលបានចុះហត្ថលេខានៅទីក្រុង ហ្សាការតា ,កាលពីថ្ងៃ ទី ១៨ ខែ មិថុនា ឆ្នាំ ១៩៨៣ និងក្រមដឹកនាំគយកែសំរួលឡើងវិញ ដែលចុះហត្ថលេខាកាលពីថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

ដោយសំរេចចិត្តជំរុញពាណិជ្ជកម្មផ្ទៃក្នុងអាស៊ាន និង ការវិនិយោគទុន ដោយធានាធ្វើអោយទន់ភ្លន់នៃចរាចរទំនិញតាមព្រំដែនឆ្លងកាត់ និង សេវាកម្មក្នុងតំបន់ ។

ដោយគិតដល់សេចក្តីត្រូវការពង្រឹងជាបន្តបន្ទាប់នូវការបង្រ្កាប និង ទប់ស្កាត់ក្នុងចំណោមរដ្ឋបាលគយអាស៊ាន ជាពិសេសទៅលើការរួមគ្នាប្រយុទ្ធប្រឆាំង ការជួញដូរខុសច្បាប់នូវគ្រឿងញៀន និងសារជាតិញៀន ។

ដោយទទួលស្គាល់នូវសេចក្តីត្រូវការ នូវគ្រឹះមួយនៃច្បាប់គយ ស្តីពីវិធានទូទៅ និង នីតិវិធី ដើម្បីធានានូវការអនុវត្តន៍ដោយទន់ភ្លន់នៃកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន និងការកែសំរួលផ្សេងៗ ជាពិសេសបញ្ហា AFTA ។

ដោយសំរេចចិត្តបង្កើតក្របខ័ណ្ឌមួយ ដើម្បីពង្រីកអោយស៊ីជំរៅកិច្ចសហប្រតិបត្តិការផ្នែកគយក្នុងអាស៊ាន និង ធ្វើផែនការសកម្មភាពអនាគតក្នុងតំបន់នេះ ។

បានឯកភាពគ្នាដូចតទៅនេះ :

## មាត្រា១

## គោលដៅ (Objectives)

គោលដៅនៃកិច្ចព្រមព្រៀងនេះ:

ក- សំរួល និង ធ្វើអោយស៊ីសង្វាក់គ្នា លើការកំណត់តំលៃគយ តារាងពន្ធគយ និង នីតិវិធីគយ ។

ខ- ដើម្បីធានានូវភាពមិនផ្លាស់ប្តូរចុះឡើងតម្លាភាព និងការអនុវត្តន៍អោយត្រឹមត្រូវនូវច្បាប់ និងបញ្ញត្តិគយ នីតិវិធីនានា និងទិសដៅរដ្ឋបាលផ្សេងៗទៀត រវាងប្រទេសជាសមាជិក ASEAN នីមួយៗ ។

គ- ធានាបាននូវប្រសិទ្ធភាពរដ្ឋបាល និង សំរួលដល់ការយកទំនិញចេញពីគយ ជំរុញពាណិជ្ជកម្ម និង

វិនិយោគក្នុងតំបន់ ។

ឃ- ស្រាវជ្រាវរកកិច្ចសហប្រតិបត្តិការចាំបាច់ផ្សេង១ទៀត ក្នុងតំបន់លើវិស័យគយ ដោយឡែកក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ និងបទល្មើសគយផ្សេង១ទៀត លើគ្រប់រូបភាព ។

## មាត្រា២

## គោលការណ៍

ប្រទេសជាសមាជិក ត្រូវអនុវត្តតាមគោលការណ៍ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងដូចតទៅ :

ក- ភាពមិនផ្លាស់ប្តូរចុះឡើង ( Consistency ): ប្រទេសជាសមាជិក ត្រូវធានានូវនិរន្តរភាពនៃការអនុវត្តន៍ច្បាប់ និងបញ្ញត្តិគយ និតិវិធី របៀបរបបរដ្ឋបាល និងការគ្រប់គ្រងផ្សេងទៀតនៅក្នុងប្រទេសជាសមាជិករបស់ ASEAN នីមួយ១ ។

ខ- សិទ្ធិសុំវិនិច្ឆ័យឡើងវិញ ( Appeal ): ប្រទេសជាសមាជិក ត្រូវធានាដល់ពាណិជ្ជករនូវសិទ្ធិសុំពិនិត្យសារឡើងវិញ លើសេចក្តីសំរេចចិត្តរបស់គយក្នុងតំបន់ តាមមធ្យោបាយដែលអាចធ្វើបាន ។

គ- ភាពសាមញ្ញ (Simplicity ): ប្រទេសជាសមាជិក ត្រូវខិតខំធានានូវភាពងាយស្រួលដល់នីតិវិធី និងកិច្ចការរបស់គយក្នុង ASEAN ។

ឃ- តម្លាភាព (Transparency ): ប្រទេសជាសមាជិក ត្រូវធ្វើអោយច្បាប់ បញ្ញត្តិនីតិវិធី និងសេចក្តីប្រកាសរដ្ឋបាល លើវិស័យសេដ្ឋកិច្ចទាំងអស់ ដែលពាក់ព័ន្ធនិងរដ្ឋបាលគយ បានទៅដល់ដៃសាធារណជនអោយបានទាន់ពេលវេលា និង ប្រកបដោយតម្លាភាព ។

ង- ប្រសិទ្ធិភាព (Efficiency ): ប្រទេសជាសមាជិក ត្រូវធានាអោយមានរដ្ឋបាលប្រកបដោយប្រសិទ្ធិភាព និង សមត្ថភាព និងធានានូវការបញ្ចេញទំនិញអោយបានលឿន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពាណិជ្ជកម្ម និង វិនិយោគក្នុងតំបន់ ASEAN ។

ច- សហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក : ប្រទេសជាសមាជិក ត្រូវព្យាយាមធ្វើសហប្រតិបត្តិការអោយពេញទំហឹង និង ជួយគ្នាទៅវិញទៅមករវាងអាជ្ញាធរគយ ។

## មាត្រា៣

## បទបញ្ញត្តិទូទៅ

១- បទបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ត្រូវតែអនុវត្តចំពោះគ្រប់ប្រទេសជាសមាជិក និងចំពោះគ្រប់មុខទំនិញ ដែលធ្វើអាជីវកម្មក្នុងតំបន់ ASEAN ដោយស្របច្បាប់ វិធាន និងបញ្ញត្តិនានា របស់ជាតិខ្លួន ។

២- ទំនិញទាំងឡាយដែលស្ថិតក្រោមសម្បទានអនុគ្រោះ ទោះបីជាជាប់ពន្ធ ឬមិនជាប់ពន្ធក៏ដោយ ហើយស្ថិតក្រោមកិច្ចព្រមព្រៀងសេដ្ឋកិច្ច ASEAN ណាមួយ ត្រូវអនុលោមទៅតាមវិធានដើមកំណើតសំរាប់ CEPT AFTA ។

## មាត្រា៤

## តារាងពន្ធគយ

(Tariff Nomenclature)

១- តារាងពន្ធគយ ត្រូវផ្អែកលើមូលដ្ឋាន ៦ខ្ទង់ នៃប្រព័ន្ធ HS របស់អង្គការ WCO (អង្គការគយពិភពលោក) និងវិសោធនកម្មរបស់ HS នេះ ។

២- ប្រទេសជាសមាជិកត្រូវប្រើតារាងពន្ធគយរួម ក្នុងកំរិត ៨ខ្ទង់ សំរាប់គោលបំណងអត្រាពន្ធគយ ។ តារាងពន្ធគយសំរបសំរួល ASEAN លើសពីកំរិត ៨ខ្ទង់ អាចត្រូវប្រើសំរាប់ការងារស្ថិតិ និងការងារផ្សេងទៀត ។

៣- ប្រទេសជាសមាជិកធ្វើវិសោធនកម្មតារាងពន្ធគយ សំរបសំរួលដោយសមស្របទៅតាមមាត្រាទី១០ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៥

## ការកំណត់តំលៃគយ

១- ប្រទេសជាសមាជិកមិនត្រូវប្រើនូវការកំណត់តំលៃគយក្នុងគោលបំណងគាំពារ ឬជារបាំងពាណិជ្ជកម្ម ។

២- ប្រទេសជាសមាជិកត្រូវអនុវត្តការកំណត់តំលៃដូចក្នុងកិច្ចព្រមព្រៀង GATT ដូចមានចែងកិច្ចព្រមព្រៀងលើការអនុវត្តន៍មាត្រា VII របស់ GATT ឆ្នាំ ១៩៩៤ តាមកម្មវិធីល្បឿន ។

៣- ប្រទេសជាសមាជិកត្រូវអនុម័ត នូវការបកស្រាយរួមមួយ នៃកិច្ចព្រមព្រៀង និងធ្វើអោយមានស្តង់ដារ ( Standard ) ដូចគ្នានូវប្រព័ន្ធនានា ដែលត្រូវបានប្រើដើម្បីប្រតិបត្តិកិច្ចព្រមព្រៀងនោះ ។

## មាត្រា៦

## នីតិវិធីគយ

១- ប្រទេសជាសមាជិកត្រូវធ្វើអោយងាយ និងធ្វើអោយស៊ីសង្វាក់គ្នា នូវនីតិវិធីគយដើម្បីអោយការបញ្ចេញទំនិញពីគយបានរហ័ស និងប្រកបដោយប្រសិទ្ធិភាពចំពោះទំនិញ ដែលធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ។

២- ការធ្វើអោយងាយ និង ការធ្វើអោយស្របគ្នា នៃនីតិវិធីគយអាស៊ាន ត្រូវស៊ីគ្នាទៅនឹងស្តង់ដារ និង

សំណូមពរអនុវត្តក្នុងអនុសញ្ញា ក្យូតូ ក៏ដូចជាការកែប្រែក្រោមការឧបត្ថម្ភពីក្រុមប្រឹក្សាសហប្រតិបត្តិការគយ CCC ឬអង្គការគយពិភពលោក WCO ។

៣- គ្មានអ្វីត្រូវបានហាមឃាត់ ចំពោះប្រទេសជាសមាជិកពីរ ឬច្រើនដែលមានបំណងសម្រួលការធ្វើពាណិជ្ជកម្ម ច្រើនជាងអាទិភាព ដែលបានផ្តល់អោយដោយកិច្ចព្រមព្រៀងនេះ ។ ប្រទេសជាសមាជិកលើកទឹកចិត្តអោយ ពង្រីកអាទិភាពទាំងនេះ ចំពោះប្រទេសជាសមាជិកដទៃទៀតយ៉ាងណាក៏បាន ។

៤- ប្រទេសជាសមាជិកត្រូវយូរៗម្តង ពិនិត្យឡើងវិញនូវនីតិវិធីគយអាស៊ាន ដោយអនុលោមតាមប្រការ ១០ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៧

## ផ្នែកផ្សេងៗទៀត នៃកិច្ចសហប្រតិបត្តិការ

១- ប្រទេសជាសមាជិកត្រូវទាញបញ្ចូលផ្នែកផ្សេង១ទៀត នៃសហប្រតិបត្តិការផ្នែកគយស្របតាមច្បាប់ វិធាន និង បញ្ញត្តិជាតិរៀង១ខ្លួន និង ស្ថិតក្នុងវង្វង់សមត្ថកិច្ចរដ្ឋបាលគយ និង ធនធានដែលមាន ។

២- ប្រទេសជាសមាជិកត្រូវបានលើកទឹកចិត្ត អោយផ្ទាស់ប្តូរពត៌មានសំខាន់១ លើបញ្ហាទប់ស្កាត់ និង បង្ក្រាប អំពើរត់ពន្ធ ចរាចរគ្រឿងញៀន និងសារធាតុញៀន ព្រមទាំងបទល្មើសគយផ្សេងទៀត ។ ផ្អែកតាមកថាខ័ណ្ឌ ១នៃមាត្រានេះ អាជ្ញាធរគយអាស៊ាន ត្រូវសហការគ្នាទៅវិញទៅមកក្នុងការដឹកនាំស្រាវជ្រាវ ស៊ើបអង្កេតពាក់ព័ន្ធនឹងការរត់ពន្ធ និង បទល្មើសគយផ្សេងទៀត ។

៣- ប្រទេសជាសមាជិកត្រូវយកចិត្តទុកដាក់ ជួយដល់រាល់សំណើណាមួយ របស់ប្រទេសជាសមាជិក ក្នុងការសិក្សាស្វែងយល់ និង ធ្វើទស្សនៈកិច្ចដោយមន្ត្រីគយ ។

៤- ប្រទេសជាសមាជិកត្រូវផ្ទាស់ប្តូរពត៌មាន លើបញ្ហាគយអន្តរជាតិ និងព្យាយាមពង្រឹងទីតាំងរបស់អាស៊ាន លើឆាកគយអន្តរជាតិ ។

៥- ប្រទេសជាសមាជិកត្រូវពង្រីកសកម្មភាពដទៃទៀត ដើម្បីពង្រឹងសហប្រតិបត្តិការផ្នែកគយក្នុងតំបន់ ។

## មាត្រា៨

## ឧទ្ធរណ៍ ( Appeals )

ផ្អែកតាមច្បាប់ និង បញ្ញត្តិជាតិនៃប្រទេសជាសមាជិកអាស៊ានទីមួយ១ បុគ្គលណាម្នាក់ដែលមានកំហុសត្រូវមានសិទ្ធិសុំអោយវិនិច្ឆ័យជាថ្មី នូវការសំរេចចិត្តដែលធ្វើឡើងដោយអាជ្ញាធរគយ នៃប្រទេសជាសមាជិកទាំងឡាយ ។

## មាត្រា៩
## ការពិគ្រោះយោបល់ និងការដោះស្រាយជំនាស់

១- ជាមួយនឹងសំណើជាលាយល័ក្ខអក្សរ ពីប្រទេសជាសមាជិកមួយ ប្រទេសជាសមាជិកទាំងឡាយត្រូវចូលរួម ក្នុងការពិគ្រោះយោបល់ ក្នុងទស្សនៈស្វែងយល់ នូវដំណោះស្រាយមួយទាន់ពេលវេលាប្រកបដោយសមធម៌ និងទទួលយកបានទៅវិញទៅមក ប្រសិនបើសមាជិកនោះមិនយល់ថា :

ក- កាតព្វកិច្ចមួយក្នុងកិច្ចព្រមព្រៀងនេះ មិនបានបំពេញកន្លងមក មិនកំពុងនឹងបំពេញ ឬនឹងមិនអាចបំពេញ ។

ខ- គោលដៅណាមួយ នៃកិច្ចព្រមព្រៀងនេះមិនអាចបំពេញបាន ឬធ្វើមិនបានសំរេច ។

២- ការខុសគ្នាណាមួយរវាងប្រទេសជាសមាជិក ក្នុងការបកស្រាយ ឬអនុវត្តន៍នូវកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយដោយមិត្តភាព រវាងភាគីនានា តាមលទ្ធភាពដែលអាចធ្វើបាន ។ ប្រសិនបើដំណោះស្រាយណាមួយមិនអាចទៅដល់ ទំនាស់ត្រូវដាក់ជូនទៅអគ្គនាយកគយអាស៊ានធ្វើការដោះស្រាយ ។ ប្រសិនបើភាពខុសគ្នា របៀបណាមួយ មិនអាចដោះស្រាយបាន វាត្រូវក្លាយជាកម្មវត្ថុ នៃយន្តការដោះស្រាយទំនាស់អាស៊ាន ( Dispute Settlement Mechanism of ASEAN ) ជាអ្នកធ្វើ ។

## មាត្រា១០
## ការកែសំរួលស្ថាប័ន

១- អគ្គនាយកគយអាស៊ាន ក្រោមការអោយយោបល់របស់ក្រុមប្រឹក្សា AFTA និង AEM ( ASEAN Econonic Ministers ) រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ត្រូវមើលឡើងវិញ កែសំរួល ត្រួតពិនិត្យមើលរាល់ទិដ្ឋភាពទាក់ទងទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀង ។

២- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវការទ្រទ្រង់សំរាប់ការត្រួតពិនិត្យ ចាត់ចែង និងមើលឡើងវិញការអនុវត្តន៍កិច្ចព្រមព្រៀង និង ជួយដល់អគ្គនាយកគយអាស៊ាន ក្នុងគ្រប់បញ្ហាពាក់ព័ន្ធនឹងកិច្ចការនេះ ។

## មាត្រា១១
## ការចូលរួមរបស់ផ្នែកឯកជន

១- ប្រទេសជាសមាជិកស្របតាមប្រការ ៦ នៃគំរោងកិច្ចព្រមព្រៀងស្តីពីការពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន (១៩៩២) ទទួលស្គាល់នូវសារៈសំខាន់ នៃការលើកទឹកចិត្តរវាងគ្នាទៅវិញទៅមកនូវកិច្ចសហប្រតិបត្តិការពិគ្រោះយោបល់ ជាមួយនឹងផ្នែកឯកជនរបស់អាស៊ាន ជាពិសេសតាមវិធី និងមធ្យោបាយនានា សំដៅពង្រឹងភាពងាយស្រួលនៃពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ។

២- ការជួបគ្នានៃអគ្គនាយកគយអាស៊ាន នឹងជាវេទិកាសំរាប់ការជ្យារភ្ជាប់របៀបនេះ ជាមួយនឹងផ្នែកឯកជន ។

## មាត្រា១២

## ការចូលរួមរបស់សមាជិកថ្មី

សមាជិកថ្មីទាំងឡាយរបស់អាស៊ាន ត្រូវចូលរួមក្នុងកិច្ចព្រមព្រៀងនេះ តាមខ្លឹមសារ និងលក្ខខ័ណ្ឌនានា ដែលបានយល់ព្រមរវាងសមាជិកថ្មីទាំងនេះ និងសមាជិកអាស៊ានទាំងឡាយដែលមានពីមុនមក ។ ការចូលរួមត្រូវ ឆ្លងកាត់ការចុះហត្ថលេខា និងប្រកាសជាលាយល័ក្ខអក្សរនូវរបៀបចូលរួមក្នុងកិច្ចព្រមព្រៀងនេះជាមួយអគ្គលេខាធិការអាស៊ាន ។

## មាត្រា១៣

## អវសានបញ្ញត្តិ

១- ដោយមានការព្រមព្រៀងពីប្រទេសជាសមាជិកទាំងអស់ បទបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ អាចពិនិត្យឡើងវិញ ឬធ្វើវិសោធនកម្ម ។

២- ឧបសម្ព័ន្ធនានា អាចត្រូវដាក់ចូលបន្ថែមលើកិច្ចព្រមព្រៀងនេះ និង បង្កើតជាបន្ថែមទៅលើកិច្ចព្រមព្រៀងនោះ ។ ការយោងណាមួយចំពោះកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ទុកជាបញ្ចូលផងដែរនូវការយោងក្នុងឧបសម្ព័ន្ធ ។

៣- ប្រទេសជាសមាជិក ត្រូវទទួលរ៉ាប់រងបង្កើតនូវវិធានការណ៍សមស្របនានា ដើម្បីបំពេញកាតព្វកិច្ចដែលចែងក្នុងកិច្ចព្រមព្រៀងនេះ ។

៤- ប្រទេសជាសមាជិកត្រូវបំពេញអោយអស់លទ្ធភាព ដោយគោរពនូវរាល់បទបញ្ញត្តិនានា នៃកិច្ចព្រមព្រៀងនេះ។

៥- កិច្ចព្រមព្រៀមនេះត្រូវតំកល់ជូនអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្តល់ជាបន្ទាន់ ចំពោះប្រទេសជាសមាជិកនីមួយៗ នូវច្បាប់ចំលងរបស់វា ដែលមានការបញ្ជាក់ការទទួលស្គាល់ ។

៦- កិច្ចព្រមព្រៀមនេះត្រូវចូលជាធរមាន ក្រោយពេលចុះហត្ថលេខា និង ប្រកាសជាលាយល័ក្ខអក្សរលើការផ្តល់សច្ចាប័ន ឬការយល់ព្រមដោយរដ្ឋាភិបាលប្រទេសហត្ថលេខីទាំងអស់ ជាមួយនឹងអគ្គលេខាធិការអាស៊ាន ។

ដើម្បីទុកជាសាក្សី អ្នកចុះហត្ថលេខាខាងក្រោម ដែលត្រូវបានអនុញ្ញាតអោយចុះហត្ថលេខាលើកិច្ចព្រមព្រៀង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរបស់អាស៊ានពីបញ្ញាគយនេះ ។